**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.១៣៥....សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្កើត "មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព" សរសេរកាត់ថា "**ម.អ.ស.**" និងមានឈ្មោះជាភាសាអង់គ្លេសថា "ENTREPRENEURSHIP DEVELOPMENT FUND" ដែលសរសេរជាអក្សរកាត់ថា "EDF" ដើម្បីកៀរគរ, វិនិយោគ និងគ្រប់គ្រងបរធនពីគ្រប់ប្រភពស្របច្បាប់នានា សម្រាប់គាំទ្រដល់ដំណើរការអភិវឌ្ឍន៍ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព តាមរយៈការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដល់សហគ្រិន, សហគ្រាសធុនតូច និងមធ្យម, ធុរកិច្ចបង្កើតថ្មី និងស្ថាប័នដៃគូ ដែលធ្វើសកម្មភាពនវានុវត្តន៍ និងបង្កើតតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច។ **ម.អ.ស.** ជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់គាំទ្រពិពិធកម្មសេដ្ឋកិច្ច, នវានុវត្តន៍ និងការបង្កើតការងារសមរម្យ។

ប្រតិបត្តិការរបស់ **ម.អ.ស.** ផ្តោតលើគោលការណ៍ចំនួន ៤ គឺ÷

- ការពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងប្រព័ន្ធបណ្តាញទំនាក់ទំនងដែលប្រមូលផ្តុំនូវកម្លាំងអន្តរកម្មរបស់គ្រប់ភាគីពាក់ព័ន្ធ,
- ការរៀបចំ និងការអនុវត្តផែនការថវិកាត្រូវផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះ,
- ការផ្តល់ថវិកាគាំទ្រ និងវិនិយោគត្រូវផ្អែកលើមូលដ្ឋានភាពជាដៃគូជាមួយវិស័យឯកជន និង
- ការរក្សាកម្រិតប្រាក់បៀវត្សសមរម្យសម្រាប់មន្ត្រី និងបុគ្គលិក ដើម្បីធានាប្រសិទ្ធភាពការងារ និងវិជ្ជាជីវៈខ្ពស់។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ កំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធី ក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅនៃ **ម.អ.ស.**។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព។

**ប្រការ៤.-**

បច្ចេកសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចបានកំណត់ខាងក្រោម÷

- **បរធន** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលបានកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **បរធនបាល** សំដៅដល់បុគ្គលដែលទទួលសិទ្ធិគ្រប់គ្រង និងចាត់ចែងបរធន ពីបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រង និងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **បរធនបាលទាយក** សំដៅដល់បុគ្គលដែលបានបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់មូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច **ម.អ.ស.**។
- **ស្ថាប័នដៃគូ** សំដៅដល់ស្ថាប័នដែលមានបេសកកម្មលើកកម្ពស់ និងបណ្តុះបណ្តាលសហគ្រិន, សហគ្រាសធុនតូច និងមធ្យម និងធុរកិច្ចបង្កើតថ្មី ដែលមានកិច្ចព្រមព្រៀងសហការជាមួយស្ថាប័នប្រតិបត្តិករក្រោមចំណុះ។
- **ស្ថាប័នប្រតិបត្តិករក្រោមចំណុះ** សំដៅដល់ "មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព" ដែលចំណុះឱ្យលេខាធិការដ្ឋាន **ម.អ.ស.** ដើម្បីអនុវត្តកម្មវិធីគាំទ្រជាប្រយោជន៍ដល់អត្ថគាហកៈ និងធ្វើការដោយផ្ទាល់ជាមួយស្ថាប័នដៃគូ។
- **អត្ថគាហកៈ** សំដៅដល់សហគ្រិន, សហគ្រាសធុនតូច និងមធ្យម, ធុរកិច្ចបង្កើតថ្មី និងស្ថាប័នដៃគូដែលធ្វើសកម្មភាពនវានុវត្តន៍ និងបង្កើតតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច។

## ជំពូកទី២
## អត្តសញ្ញាណ ប្រភពធនធាន និងបរធនបាលកិច្ច នៃ ម.អ.ស.
### ផ្នែកទី១
### អត្តសញ្ញាណ និងប្រភពធនធាន

**ប្រការ៥.-**

**ម.អ.ស.** ជាបរធនបាលកិច្ចសាធារណៈ ដែលបង្កើតឡើង ដើម្បីកៀរគរ, វិនិយោគ និងគ្រប់គ្រង

បរធនពីប្រភពស្របច្បាប់, មិនស្វែងរកប្រាក់កម្រៃជាឯកជន, មិនប្រកាន់ពូជសាសន៍ សាសនា និន្នាការនយោបាយ និងបម្រើផលប្រយោជន៍ឱ្យអត្ថគាហកៈ។

**ម.អ.ស.** អាចមានធនធានពីប្រភពដូចតទៅ÷

- វិភាគទានប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- វិភាគទានពីគ្រប់ប្រភពស្របច្បាប់ផ្សេងៗទៀត។

## ផ្នែកទី២
## បរធនបាលកិច្ច នៃ ម.អ.ស.

**ប្រការ៦.-**

បរធនបាលទាយក គឺជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បរធនបាលកិច្ចត្រូវស្ថិតក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.**។

**ប្រការ៧.-**

**ម.អ.ស.** មានរូបសញ្ញា និងត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល។

**ម.អ.ស.** មានទីស្នាក់ការកណ្តាលនៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថិតនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគត ជាកម្មវត្ថុនៃការសម្រេចរបស់ក្រុមប្រឹក្សាបរធន-បាល **ម.អ.ស.**។

## ជំពូកទី៣
## សមាសភាព រចនាសម្ព័ន្ធ តួនាទី និងសិទ្ធិអំណាច

## ផ្នែកទី១
## ក្រុមប្រឹក្សាបរធនបាល

**ប្រការ៨.-**

ក្រុមប្រឹក្សាបរធនបាល មានសមាសភាពដូចខាងក្រោម÷

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានកិត្តិយស

| | | |
|---|---|---|
| - | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (០១ រូប) | ប្រធាន |
| - | តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (០១ រូប) | អនុប្រធាន |
| - | តំណាងវិស័យឯកជន (០២ រូប) | សមាជិក |
| - | តំណាងស្ថាប័ននវានុវត្តន៍ ឬបណ្ដុះធុរកិច្ចបង្កើតថ្មី (០១ រូប) | សមាជិក |
| - | ប្រធានលេខាធិការដ្ឋាន **ម.អ.ស.** | សមាជិក ។ |

សមាសភាពជាក់ស្ដែងរបស់ក្រុមប្រឹក្សាបរធនបាល ត្រូវតែងតាំង និងផ្លាស់ប្ដូរដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តទៀតបាន តាមសំណើរបស់ស្ថាប័នដែលសមាជិកនោះជាតំណាង។

**ប្រការ៩.-**

ក្រុមប្រឹក្សាបរធនបាល មានតួនាទី សិទ្ធិ និងអំណាច ដូចខាងក្រោម÷

- ពិនិត្យ និងអនុម័តផែនការថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ម.អ.ស.**,
- អនុម័តលើបទបញ្ញាផ្ទៃក្នុងរបស់ **ម.អ.ស.**,
- ធ្វើការកៀរគរធនធានហិរញ្ញវត្ថុ និងសម្ភារៈនានា ដើម្បីបម្រើដល់គោលបំណង និងគោលដៅដូចមានចែងក្នុងប្រការខាងលើ,
- ផ្ដល់ការណែនាំគោលនយោបាយ និងដាក់ចេញនូវបែបបទ និងនីតិវិធីចាំបាច់នានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងដំណើរការនៃ **ម.អ.ស.** ដើម្បីធានាឱ្យបាននូវយន្តការប្រតិតុល្យភាពគ្រប់គ្រង និងស្វ័យភាពរដ្ឋបាលក្នុងដំណើរការអនុវត្តថវិកា និង
- ធានាការប្រើប្រាស់ថវិកាប្រកបដោយតម្លាភាព, ប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាព។

**ប្រការ១០.-**

ដំណើរការការងាររបស់ក្រុមប្រឹក្សាបរធនបាល ត្រូវកំណត់ដោយបទបញ្ញាផ្ទៃក្នុងរបស់ **ម.អ.ស.** ។

**ប្រការ១១.-**

ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ត្រូវប្រជុំការងារយ៉ាងតិចមួយដង ក្នុងមួយឆ្នាំ ឬអាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាបរធនបាល។ ករណីចាំបាច់ ប្រធានក្រុមប្រឹក្សាបរធនបាលអាចប្រគល់សិទ្ធិឱ្យអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស។

កិច្ចប្រជុំក្រុមប្រឹក្សាបរធនបាលអាចដំណើរការបាន លុះត្រាតែមានវត្តមាននៃសមាជិកយ៉ាងតិចពីរភាគបី។

ប្រធានក្រុមប្រឹក្សាបរធនបាល អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ននានា ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាបរធនបាល និងឥស្សរជននានា ដែលមានបទពិសោធន៍ក្នុងវិស័យវិទ្យាសាស្ត្រសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ធុរកិច្ច, បច្ចេកវិទ្យា និងសង្គមកិច្ច ឱ្យចូលរួមកិច្ចប្រជុំដើម្បីផ្តល់មតិយោបល់។

**ប្រការ១២.-**

កំណត់ហេតុកិច្ចប្រជុំ ត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ **ម.អ.ស.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាបរធនបាលទាំងអស់ដែលបានចូលរួមក្នុងអង្គប្រជុំ។

## ផ្នែកទី២
## ប្រធានក្រុមប្រឹក្សាបរធនបាល

**ប្រការ១៣.-**

ប្រធានក្រុមប្រឹក្សាបរធនបាល មានភារកិច្ចសម្របសម្រួល និងអនុវត្តការងារដូចតទៅ÷

- អនុម័តលើសំណើសុំគោលការណ៍អនុវត្តផែនការសកម្មភាពនិងថវិការបស់លេខាធិការដ្ឋាន **ម.អ.ស.** ដែលក្រុមប្រឹក្សាបរធនបាល បានអនុម័តរួចលើផែនការថវិកាប្រចាំឆ្នាំ និង
- ធ្វើជាគណៈអធិបតីក្នុងកិច្ចការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន ឬមូលនិធិនានា ដើម្បីភាពរីកចម្រើន និងចីរភាពនៃ **ម.អ.ស.**។

## ផ្នែកទី ៣
## លេខាធិការដ្ឋាន ម.អ.ស.

**ប្រការ១៤.-**

**ម.អ.ស.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការផ្នែករដ្ឋបាល និងបច្ចេកទេស ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពនៃកិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ១៥.-**

លេខាធិការដ្ឋាន **ម.អ.ស.** មានភារកិច្ចជាអាទិ៍÷

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.**,

- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ **ម.អ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាលពិនិត្យ និងអនុម័ត,
- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ, ផែនការថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ម.អ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល ពិនិត្យ និងសម្រេច,
- រៀបចំ និងត្រួតពិនិត្យ និងវាយតម្លៃការប្រព្រឹត្តទៅរបស់ "មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព",
- ជាតំណាងរបស់ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.** ក្នុងការទំនាក់ទំនងជាមួយសាធារណជន និង
- អនុវត្តភារកិច្ចដទៃទៀតតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល **ម.អ.ស.**។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន **ម.អ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៦.-**

លេខាធិការដ្ឋាន ដឹកនាំដោយប្រធាន ០១រូប និងមានមន្ត្រីមួយចំនួន។ សមាសភាពជាក់ស្ដែងនឹងត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លេខាធិការដ្ឋាន ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ដែលមានគុណវុឌ្ឍិការងារពាក់ព័ន្ធ ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់ និងធានាបានប្រសិទ្ធភាពការងាររបស់ខ្លួន។

## ជំពូកទី៤

## ការគ្រប់គ្រងហិរញ្ញវត្ថុ ម.អ.ស.

### ផ្នែកទី១

### ការរក្សាធនធានហិរញ្ញវត្ថុរបស់ ម.អ.ស.

**ប្រការ១៧.-**

ធនធានហិរញ្ញវត្ថុនៃ **ម.អ.ស.** ត្រូវរក្សាទុកនៅក្នុងគណនីនៅធនាគារណាមួយក្រោមឈ្មោះផ្ទាល់របស់គណនី **ម.អ.ស.** និងក្រោមរូបភាពជាការវិនិយោគដែលអនុម័តដោយក្រុមប្រឹក្សាបរធនបាល។

### ផ្នែកទី២

### ធនធានហិរញ្ញវត្ថុសម្រាប់ដំណើរការ ម.អ.ស.

**ប្រការ១៨.-**

ចំណាយសម្រាប់ការប្រព្រឹត្តទៅ និងការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាបរធនបាល និងលេខាធិ-

ការដ្ឋាន **ម.អ.ស.** ត្រូវគ្រោងក្នុងគម្រោងថវិកាប្រចាំឆ្នាំ ដែលមានប្រភពថវិកាឧបត្ថម្ភកធនពីរដ្ឋក្នុងកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រភពស្របច្បាប់ផ្សេងៗទៀត។

ការទូទាត់ និងការបើកប្រាក់ ត្រូវសម្រេចដោយប្រធានក្រុមប្រឹក្សាភិបាល **ម.អ.ស.**។ ប្រធានក្រុមប្រឹក្សាភិបាល **ម.អ.ស.** អាចផ្តល់សិទ្ធិដល់អនុប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានលេខាធិការដ្ឋាន ដើម្បីអនុវត្តការងារទូទាត់ និងបើកប្រាក់។

## ផ្នែកទី៣

## ការបើកផ្តល់ថវិកាដល់អត្ថគាហកៈ និងការវិនិយោគ

**ប្រការ១៩.**-

ការបើកផ្តល់ថវិកាដល់អត្ថគាហកៈ មានដូចជាសហគ្រិន, សហគ្រាសធុនតូច និងមធ្យម, ធុរកិច្ចបង្កើតថ្មី និងស្ថាប័នដៃគូ និងការវិនិយោគ **ម.អ.ស.** ត្រូវផ្អែកតាមសំណើសុំរបស់ស្ថាប័នប្រតិបត្តិករក្រោមចំណុះ ដែលត្រូវដាក់មកលេខាធិការដ្ឋាន ដើម្បីពិនិត្យ និងដាក់ជូនក្រុមប្រឹក្សាភិបាល **ម.អ.ស.** ពិនិត្យ និងសម្រេច។

**ប្រការ២០.**-

ស្ថាប័នប្រតិបត្តិករក្រោមចំណុះ ចាំបាច់ត្រូវកត់ត្រារាល់ចំណាយស្របតាមប្រព័ន្ធស្តង់ដារគណនេយ្យកម្ពុជា, រក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហើយផ្តល់ជូនលេខាធិការដ្ឋាន ដើម្បីបូកសរុប និងដាក់ជូនក្រុមប្រឹក្សាភិបាល **ម.អ.ស.** ពិនិត្យ និងសម្រេច។

## ផ្នែកទី៤

## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ២១.**-

ការគ្រប់គ្រង និងប្រើប្រាស់ថវិការបស់ **ម.អ.ស.** ជាកម្មវត្ថុនៃការធ្វើសវនកម្ម ដោយសវនករឯករាជ្យ។

**ប្រការ២២.**-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញសេចក្តីសម្រេច ស្តីពីនីតិវិធីអនុវត្តថវិកាលម្អិតបន្ថែម តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា **ម.អ.ស.**។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ